**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**នៃព្រះរាជាណាចក្រកម្ពុជា**

*សម្តេច,*

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លាដែលសម្តេច ត្រូវបានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ប្រោសព្រះរាជទានគោរមងារជា **សម្តេចក្រឡាហោម ស ខេង** ខ្ញុំក្នុងនាមថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសេចក្តីរំភើបរីករាយឥតឧបមា សូមសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅជូនសម្តេច ។

គោរមងារជា **សម្តេចក្រឡាហោម** ជាសក្ខីភាពបង្ហាញឱ្យឃើញនូវសមត្ថភាពការងារ និង កិច្ចខិតខំប្រឹងប្រែងដែលសម្តេចបានរួមចំណែកក្នុងការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសូមជូនពរ **សម្តេចក្រឡាហោម** មានសុខភាពល្អ និង ទទួលបាននូវជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមដើម្បីបម្រើជាតិមាតុភូមិរបស់សម្តេច ។

សូមសម្តេចទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**
**និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

អៀង_មូលី

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៥